របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងារ
ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២២

កិច្ចប្រជុំរួមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែមីនា ឆ្នាំ២០២២

ថ្ងៃពុធ ១៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២

អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

មាតិកានុក្រម

១ សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២ សកម្មភាពការងារចម្បងៗ និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន

៣ លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៣

៤ បញ្ហាប្រឈម

៥ ទិសដៅអនុវត្តបន្ត

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចាប់មគ្គុទ្ទេសក៍ផ្ទៃក្នុង

- ឯកឧត្តមទេសរដ្ឋមន្ត្រី បានពិនិត្យ និងសម្រេចលើសកម្មភាពនានារបស់ អ.ជ.ប.ជ.អ។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានជួបប្រជុំពិភាក្សាការងារបច្ចេកទេសជាមួយថ្នាក់ដឹកនាំរបស់ អ.ជ.ប.ជ.អ និងបានផ្តល់អនុសាសន៍ពីនីតិវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងលើកទិសដៅផែនការសកម្មភាពរបស់ អ.ជ.ប.ជ.អ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការងារមន្ត្រីទេសក៏ផ្ទៃក្នុង

- ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ២០២២ ខួបលើកទី១១១ ក្រោមប្រធានបទ "សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត"

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចារមគ្គទេសក៍ផ្ទៃក្នុង(ត):

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំជាន់ខ្ពស់ ប្រចាំត្រីមាសលើកទី៣ ស្តីពីគម្រោងផ្តួចផ្តើមទីក្រុងពន្លឿនការឆ្លើយតបនឹងមេរោគអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចាររាជរដ្ឋាភិបាល :

- ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវជាតិលេខ៣ ភ្នំពេញ-កំពត។

ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចារកេជរដ្ឋាភិបាល (ត)

ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមន្ទីពេទ្យមិត្តភាពកម្ពុជា- ចិន តំបូងឃ្មុំ សាលាបឋមសិក្សា និងវិទ្យាល័យតេជោសែនតំបូងឃ្មុំ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចារកម្មរដ្ឋាភិបាល (ត)

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការភូមិកុមារ SOS ព្រៃវែង។

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចារកម្មរដ្ឋាភិបាល (ត)

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មន្ទីរពេទ្យមិត្តភាពកម្ពុជា- ចិន ព្រះកុសមៈ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចារកម្មរដ្ឋាភិបាល (ត)

ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ២១

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចារកម្មរដ្ឋាភិបាល (ត)

ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥១

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការចាររាជរដ្ឋានិបាល (ត)

នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធវិមាននៃការចងចាំ (អតីតទំនប់អាកាព ហៅម.៤០១ នៅភូមិត្រពាំងពើក ឃុំកាត់ក្លុក ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ)

ឯកឧត្តមទេសរដ្ឋមន្ត្រី

២- ការងាររាជរដ្ឋាភិបាល (ត)

ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២១ និងទិសដៅការងារ ឆ្នាំ២០២២របស់រដ្ឋបាលខេត្តកំពង់ស្ពឺ

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ ផ្តល់យោបល់ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការងារផ្ទៃក្នុងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីនិរន្តភាពនៃដំណើរការផ្ទៃក្នុង អ.ជ.ប.ជ.អ។

ឯកឧត្តម គង់ រដ្ឋា

- នាព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញចូលរួមជ័ខ្ពង់ខ្ពស់ក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ២០២២ ខួបលើកទី១១១ ក្រោមប្រធានបទ "សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត"
- នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ បានអញ្ជើញជា អធិបតីជ័ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធវិមាននៃការចងចាំ (អតីតទំនប់អាកាព ហៅម.៤០១ នៅភូមិត្រពាំងពើក ឃុំកាត់ភ្លុក ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ)។

លោកជំទាវ ស៊ឹម ខេងខាំ

- ចូលរួមកិច្ចប្រជុំប្រចាំខែកុម្ភៈ ឆ្នាំ២០២១។
- ចូលរួមប្រារព្ធពិធី ទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២២ ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍។
- ចុះបេសកកម្មទៅខេត្ត ព្រះសីហនុ។
- ដឹកនាំកិច្ចប្រជុំក្រុមការងារយេនឌ័រ ស្តីពីការកំណត់ទិសដៅការងារយេនឌ័រសម្រាប់អនុវត្តក្នុងឆ្នាំ ២០២២ និងការរៀបចំបង្កើត ឲ្យមានក្រុមលេខាធិការ។
- ចូលរួមកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិនិត្យ និងសម្រេចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី តាមប្រព័ន្ធ វីដេអូ Zoom។
- ចូលរួមកិច្ចប្រជុំជាន់ខ្ពស់ប្រចាំត្រីមាសលើកទី៣ ស្តីពីគម្រោងផ្ទេរផ្តើមទីក្រុងពន្លឿនឆ្លើយតបនឹង ជំងឺអេដស៍

ឯកឧត្តម ស៊ឹម គឹមសៃន

- បានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែកុម្ភៈ របស់ថ្នាក់ដឹកនាំ។
- បានចូលរួមក្នុងទិវាសិទ្ធនារីអន្តរជាតិ៨មិនាឆ្នាំ២០២២។
- **ផែនការសកម្មភាពសម្រាប់ខែបន្ទាប់**
- ត្រៀមចូលរួមកិច្ចប្រជុំនានាតាមការចាត់តាំងរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

ឯកឧត្តម តែង គន្ធី

- ចូលរួមកិច្ចប្រជុំប្រចាំខែរបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចុះបំពេញបេសកម្ម និងតាមដានការងារក្រុមបុរសរួមភេទជាមួយបុរស និងប្លែងភេទ នៅខេត្តប៉ៃលិន ។
- ចូលរួមប្រជុំកម្មវិធី Fast Track Cityអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម រស់ សីលវ៉ាត់

- ចូលរួមប្រជុំថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ. ប្រចាំខែកុម្ភៈ២០២២។
- ជួបប្រជុំជាមួយឯកឧត្តមប្រធាន រាយការណ៍ពីវឌ្ឍនភាព និងស្នើសុំមតិដឹកនាំលើការងារតាមដានការអនុវត្តការងារនៅខេត្ត FTC។
- បានចូលរួមប្រជុំអន្តរក្រសួងកម្រិតនយោបាយរៀបចំដោយក្រសួងផែនការ។
- ចូលរួមប្រជុំប្រចាំត្រីមាសរាជធានីខេត្ត FTC ដើម្បីតាមដាននិងជម្រុញការអនុវត្តផែនការការងារក្រោមថវិកាជាតិ ៨០លានរៀល។
- ចូលរួមប្រជុំសិក្ខាសាលាពិគ្រោះយោបល់កម្រិតនយោបាយស្តីពីសេចក្តីព្រាងផែនការសកម្មភាព ២០២២ -២០២៤។
- ចូលរួមពិធីសម្ពោធវិមានចងចាំនៅឃុំកាត់ភ្លុក ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

ឯកឧត្តម រស់ សីលវ៉ាត់ (ក)

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ចូលរួមតាមដានការងារ FTC ក្នុងរាជធានី និងខេត្ត៣ទៀត។
- ចូលរួមផ្តល់ធាតុចូលដល់សេចក្តីព្រាងផែនការវិនិយោគបីឆ្នាំរំកិលដែលអគ្គលេខាធិការដ្ឋានកំពុងរៀបចំ សម្រាប់បញ្ជូនទៅក្រសួងផែនការ។

ឯកឧត្តម ជា ពៅ

- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកុម្ភៈ ឆ្នាំ២០២២។
- ចូលរួមពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ២០២២ ខួបលើកទី១១១ ក្រោមប្រធានបទ "សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត"
- បានផុសក្នុងហ្វេសបុកផេកសរុបចំនួន ៧ដង ត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

ឯកឧត្តម ជា ដៅ (ត)

សំណូមពរ

ស្នើសុំថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសទាំងអស់ ដែលបានចុះបំពេញការងារ សិក្ខាសាលា កិច្ចប្រជុំ ផ្សេងៗ ជួយផ្តល់អត្ថបទព័ត៌មានខ្លី ភ្ជាប់ជាមួយរូបភាព ដើម្បីយកមកផុសក្នុង Facebook Page អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ហោ ប៊ុនឡេង

- បានពិនិត្យលើសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីគោលការណ៍ណែនាំផ្តល់ប្រាក់បៀសកកម្មនិងថ្លៃធ្វើដំណើរក្នុងកម្មវិធីមូលនិធិសកល។
- បានចូលរួមពិភាក្សាជាមួយក្រុមការងារក្រសួងកិច្ចការនារី លើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រឆ្នាំ២០២១-២០៣៥របស់រាជរដ្ឋាភិបាលកម្ពុជា។
- បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកុម្ភៈឆ្នាំ២០២២។
- បានពិនិត្យយ៉ាងម៉ត់ចត់ទៅលើទម្រង់របាយការណ៍គំរូសម្រាប់អង្គប្រជុំក្រុមប្រឹក្សាបច្ចេកទេស និងអង្គប្រជុំថ្នាក់ដឹកនាំ។
- បានចូលរួមជាមួយក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិក្នុងការរៀបចំផែនការសកម្មភាពត្រីមាសទី៣ខែមេសា-ឧសភា ។

ឯកឧត្តម ហោ ប៊ុនឡេង (ត)

- បានចូលរួមរៀបចំការបង្ហាបចំណេះដឹងស្តីពីជំងឺកូវីដ-១៩ទៅក្នុងកូនសៀវភៅចំណេះដឹងដឹងស្តីពីជំងឺអេដស៍ និងសុខភាពមាតានិងទារក។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- តាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

ឯកឧត្តម ស៊ឹម គឹមសាន

- បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែ កុម្ភៈ ឆ្នាំ២០២២ ។
- បានចូលរួមប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិ ៨ មីនា ខួបលើកទី១១១។
- បានចូលរួមក្នុងពិធីសម្ពោធដាក់អោយដំណើរការមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- តាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

២

សកម្មភាពការងារចម្បងៗ និងលទ្ធផលការងារ

របស់អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ.

- បានចូលរួមកិច្ចប្រជុំរួមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី**។
- បានប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ពិនិត្យវឌ្ឍនភាពការងារ និងដាក់ទិសដៅ។
- បានរៀបចំរបាយការណ៍ស្តីពីមេរោគអេដស៍សកលឆ្នាំ២០២១ (Global AIDS Monitoring 2021)។
- រៀបចំផ្តល់ធាតុចូលលើសេចក្តីព្រាងចុងក្រោយឯកសារគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ តាមសំណើរបស់ក្រសួងកិច្ចការនារី។
- បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការត្រួតពិនិត្យតាមដានការអនុវត្តសេចក្តីណែនាំ សជណ ២១៣ (ខេត្តបន្ទាយមានជ័យ សៀមរាប បាត់ដំបង និងកំពង់ចាម)។
- ចូលរួមបើកអង្គសិក្ខាសាលាស្តីអំពីការបង្កើតសារអប់រំសម្រាប់អ្នកអប់រំផ្ទាល់ និងអ្នកផ្តល់សេវាសុខភាពសហគមន៍ និងពិធីផ្សព្វផ្សាយនៃការអនុវត្តគម្រោង "បង្កើនការទទួលបានសារអប់រំបង្ការមេរោគអេដស៍ តាមរយៈប្រព័ន្ធឌីជីថល ក្នុងចំណោមយុវជនងាយរងគ្រោះនៅកម្ពុជា" ដែលរៀបចំដោយអង្គការ KHANA និងក្រុមហ៊ុន Via Cambodia មានសិក្ខាកាមមកពីអង្គការសហគមន៍ដែលអនុវត្តផ្ទាល់ជាមួយក្រុមគោលដៅរាជធានី ខេត្ត នៅសណ្ឋាគារប៉ូឡូវៃ រាជធានីភ្នំពេញ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. (ត)

- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងរៀបចំកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ ឆ្នាំរំកិល រៀបចំដោយក្រសួងផែនការ នៅខេត្តសៀមរាប។
- បានចូលរួមអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២២ ខួបលើកទី១១១ ក្រោមប្រធានបទ "សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមកិច្ចប្រជុំពិនិត្យសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ២០១៩-២០២៣ រៀបចំដោយក្រសួងផែនការ។
- បានកែសម្រួលសូចនាករមួយចំនួននៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ដែលត្រូវដាក់បញ្ចូលក្នុងសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ២០១៩-២០២៣ រៀបចំដោយក្រសួងផែនការ។
- បានផ្តល់ធាតុចូលលើសេចក្តីព្រាងចុងក្រោយឯកសារគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ តាមសំណើរបស់ក្រសួងកិច្ចការនារី។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. (ត)

- បានចូលរួមកិច្ចប្រជុំប្រចាំត្រីមាសស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោងទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍អេដស៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី**។
- បានធ្វើការទំនាក់ទំនងជាមួយអគ្គនាយកដ្ឋានថវិការដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំសេចក្តីព្រាងប្រកាសស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីព្រាងប្រកាសស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់ស្តីពីវិធាន និងនីតិវិធីចំណាយប្រាក់បៀសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បើកវគ្គបណ្តុះបណ្តាលស្តីពីដំនាញពង្រឹងស្ថាប័នក្នុងការតាមដានលើការអនុវត្តលិខិតលេខ២១៣ សជណ.សស នៅសណ្ឋាគារហ៊ីម៉ារ៉ាវី រាជធានីភ្នំពេញ។
- ចូលរួមសិក្ខាសាលាស្តីពីពង្រឹងការអនុវត្តការងារយេនឌ័រឆ្លើយតបមេរោគអេដ្ស៍ និងជំងឺអេដស៍ឆ្នាំ២០២២ ក្រោមអធិបតីភាព **លោកជំទាវ ស៊ឹម ខេងខាំ** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានប្រជុំក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ. លើកទី៣ ឆ្នាំ២០២២។
- បានអនុវត្តគម្រោងមូលនិធិសកល៖ សិក្ខាសាលា៣លើក ប្រជុំ១លើក និងបេសកកម្ម៤លើក។
- បានដំណើរការថវិកាជាតិតាមនីតិវិធីហិរញ្ញវត្ថុ សំណើសុំថវិកា ទូទាត់ថវិកា និងដកថវិកាបានចំនួន៧លើក។
- បានគោរពផ្តល់យោបល់លើការងាររដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេសផ្សេងៗទៀតជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី**។

៣

លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៣

Updates of the National Program for Prevention of mother to Child Transmission of HIV

Component of Strategy I: Deliver Comprehensive Prevention, Care and Treatment Services via a Multisectoral Response

Agenda for Third Technical Advisory Board Meeting
Report to NAA Leaders' Monthly Meeting
March 30, 2022

Source: Dr. Chhorn Samnang, MD.,MPH Local Technical Assistant National Maternal and Child Health Centre

បញ្ហាប្រឈម

- ភាពធូរស្រាលនៃស្ថានភាពជំងឺកូវីដ១៩ បានធ្វើឱ្យសកម្មភាពនៃការចុះបេសកកម្មនៅតាមបណ្តាខេត្តមានការកើនឡើង អាចប៉ះពាល់ដល់ការផ្គត់ផ្គង់រថយន្ត និងមន្ត្រី។

៥

ទិសដៅអនុវត្តបន្ត

ទិសដៅអនុវត្តបន្ត

- បន្តអនុវត្តសកម្មភាពតាមផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ឆ្នាំ២០២២។
- បន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ តាមបណ្តារាជធានី ខេត្តគោលដៅ។
- បន្តសហការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមបណ្តារាជធានី ខេត្តគោលដៅ។
- ចងក្រង និងបញ្ចូនទិន្នន័យរៀបចំរបាយការណ៍ស្តីពីមេរោគអេដស៍សកលឆ្នាំ២០២១ (Global AIDS Monitoring 2021) (Global AIDS Monitoring 2021)
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៤។
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសដើម្បីប្រមូលធាតុចូលរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការប្រុងប្រយ័ត្នជា សកល ចំពោះការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។
- រៀបចំប្រជុំក្រុមការងាររាយតម្លៃលក្ខណសម្បត្តិគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី**។
- បំពេញការងារផ្សេងៗតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី**។

សូមអរគុណ!